

# ទទួលពរដើម្បីផ្តល់ពរ
## 8. BLESSED TO BE A BLESSING
Copyright © 2004, 2018 Barnabas Mam



វត្ថុបំណង
រៀនឲ្យដឹងថា
តើអ្នកបានទទួលពររួមជាមួយលោកអប្រាហាំដើម្បីអ្វី
តើការផ្តល់ពរដោយឥរិយាបថត្រឹមត្រូវមានគុណប្រយោជន៍យ៉ាងណា
ដើម្បីឲ្យអ្នកកាន់តែរីកចម្រើនយ៉ាងបរិបូណ៌គ្រប់វិស័យ
ក្នុងនាមជាអ្នកទទួលពរនិងជាអ្នកផ្តល់ពរ។

## ព្រះយេស៊ូបង្រៀនយ៉ាងច្រើនអំពីប្រាក់កាសនិងទ្រព្យសម្បត្តិ
JESUS TEACHES A LOT ABOUT MONEY AND WEALTH

- ក្នុងចំណោមរឿងប្រស្នាទាំង៣៨រឿង
  មានរឿងប្រស្នា១៦រឿងនិយាយអំពីប្រាក់កាសនិងទ្រព្យសម្បត្តិ
- នៅក្នុងព្រះគម្ពីរទាំងមូល
  មានខគម្ពីរ៥០០ខនិយាយអំពីការអធិស្ឋាន
- នៅក្នុងព្រះគម្ពីរទាំងមូល
  មានខគម្ពីរ៥០០ខនិយាយអំពីជំនឿ
- នៅក្នុងព្រះគម្ពីរទាំងមូល
  មានខគម្ពីរ២៣០០ខនិយាយប្រាក់កាសនិងទ្រព្យសម្បត្តិ។

ព្រះយេស៊ូមានបំណងចង់ឲ្យយើងចេះគ្រប់គ្រងប្រាក់កាសដោយឈ្លាសវៃ។

## ១.លោកអប្រាហាំជាអ្នកទទួលពរផងនិងជាអ្នកផ្តល់ពរផង
1. ABRAHAM WAS BLESSED TO BE A BLEESING

លោកុប្បត្តិ ១២:១-២

១ ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកអាប់រ៉ាមថា៖
«ចូរចាកចេញពីស្រុករបស់អ្នក ចាកចេញពីញាតិសន្តាន
និងចាកចេញពីក្រុមគ្រួសារឪពុករបស់អ្នកតម្រង់ឆ្ពោះទៅស្រុកដែលយើងនឹងបង្ហាញអ្នក។
២ យើងនឹងឲ្យប្រជាជាតិមួយដ៏ធំកើតចេញពីអ្នក
ហើយយើង នឹងឲ្យពរ អ្នក។ យើងនឹងធ្វើឲ្យអ្នក មានឈ្មោះល្បី។
ដូច្នេះ ចូរធ្វើជា អ្នកផ្តល់ពរ ដល់អ្នកដទៃចុះ!។

ព្រះជាម្ចាស់ប្រទានពរដល់លោកអប្រាហាំក្នុងគោលបំណងបីយ៉ាងគឺ
ឲ្យលោកក្លាយជាអ្នកទទួលពរ(He would be a blessed person)
ឲ្យលោកមានកេរ្តិ៍ឈ្មោះល្បី(He would be a man of great name)
និងឲ្យលោកធ្វើជាអ្នកផ្តល់ពរដល់មនុស្សជាច្រើន(He would be a blessing to many)។

២.យើងក៏ជាអ្នកទទួលពរផងនិងជាអ្នកផ្តល់ពរផងដែរ

2. WE ARE ALSO BLESSED TO BE A BLESSING

២កូរិនថូស ៩:៨-៩

៨ ព្រះអង្គអាចនឹងប្រទានពរដ៏ហូរហៀរគ្រប់យ៉ាងដល់បងប្អូន
ដើម្បីឲ្យបងប្អូន មាន អ្វីៗទាំងអស់ដែលបងប្អូនត្រូវការដ៏ចាំបាច់នោះជានិច្ច
ហើយថែមទាំងនៅសល់បរិបូណ៌សំរាប់ ចែកទាន ផង
៩ ដូចមានចែងទុកមកថា:«ព្រះអង្គចែក ព្រះអង្គប្រទានឲ្យអ្នកក្រ
សេចក្តីសុចរិតរបស់ព្រះអង្គនៅស្ថិតស្ថេរហូតតរៀងទៅ»។

យើងអាចធ្វើជាអ្នកផ្តល់ពរ

តាមរយៈការថ្វាយកម្លាំង(strength) ពេលវេលា(time) ការងារ(work) ជំនាញ(skills) ឬទ្រព្យសម្បត្តិ(wealth) ដូចជាប្រាក់កាស ម្ហូបអាហារ ដីធ្លី ផ្ទះសម្បែង ។ល។ របស់យើង សម្រាប់ចែកដល់អ្នកណាឬស្ថាប័នណាដែលព្រះវិញ្ញាណនាំចិត្តយើង។

ក.យើងបានទទួលពររួមជាមួយលោកអប្រាហាំ

A. WE ARE BLESSED ALONG WITH ABRAHAM

កាឡាទី ៣:៧,៩,១៤

៧ ក្នុងដូច្នេះសូមបងប្អូនយល់ថាអ្នកណាមានជំនឿ
អ្នកនោះហើយជាកូនចៅរបស់លោកអប្រាហាំ។
៩ ហេតុនេះ អស់អ្នកដែលមានជំនឿ
ក៏ បានទទួលព្រះពរ រួមជាមួយលោកអប្រាហាំ
ដែលជាអ្នកមានជំនឿនោះដែរ។
១៤ ហេតុការណ៍នេះកើតមានដូច្នេះ
ដើម្បីឲ្យព្រះពរដែលលោកអប្រាហាំទទួល
បានហូរទៅដល់សាសន៍ដទៃតាមរយៈព្រះគ្រិស្តយេស៊ូដែរ
ហើយឲ្យយើងទទួលព្រះវិញ្ញាណ
ដែលព្រះជាម្ចាស់បានសន្យាប្រទានមកដោយយើងមានជំនឿ។

## ខ.ពរដែលយើងត្រូវទទួលរួមជាមួយលោកអប្រាហាំ

B. THE BLESSING WE ARE TO RECEIVE WITH ABRAHAM

អ្នកមានជំនឿលើព្រះគ្រិស្តបានទទួលពររួមជាមួយលោកអប្រាហាំដូចតទៅៈ

- ពរខាងសង្គម – មានគេស្រឡាញ់រាប់អាន( លោកុប្បត្តិ ១២:២,១៦ )
- ពរខាងសម្ភារៈ – មានជីវភាពសំបូណ៌សប្បាយ( លោកុប្បត្តិ ១៣:១-២ )
- ពរខាងសតិបញ្ញា – មានប្រាជ្ញានិងសុភនិច្ច័យ( លោកុប្បត្តិ ១៥:២-៤ )
- ពរខាងរូបកាយ – មានសុខភាពល្អនិងអាយុយឺនយូរ( លោកុប្បត្តិ ១៥:១៥; ២៥:៧-៨ )
- ពរខាងប្រជាជន – ជាឪពុករបស់ប្រជាជាតិដ៏ច្រើន
  គឺឪពុករបស់កូនធម្មតានិងឪពុករបស់កូនខាងវិញ្ញាណ( លោកុប្បត្តិ ១៧:២-៦ )
- ពរខាងអាជ្ញាសិទ្ធិ – មានអំណាចលើពួកខ្មាំងសត្រូវទាំងអស់( លោកុប្បត្តិ ២២:១៧ )
- ពរខាងវិញ្ញាណ – ចូលក្នុងព្រះរាជ្យនៃស្ថានបរមសុខ( ម៉ាថាយ ៨:១០-១១ )។

## គ.យើងផ្តល់ពរក្នុងនាមជាមនុស្សដែលរីកចម្រើនឡើងយ៉ាងបរិបូណ៌

C. WE GIVE AS PEOPLE WHO EXCEL IN EVERYTHING

២កូរិនថូស ៨:៦-៧

៦ ក្នុងហេតុនេះហើយបានជាយើងអង្វរលោកទីតុស
ឲ្យមកបង្ហើយការប្រមូលតង្វាយនេះពីបងប្អូនដូចគាត់បានចាប់ផ្តើមរួចមកហើយ។
៧ បងប្អូន បានចំរើនឡើង យ៉ាងបរិបូណ៌គ្រប់វិស័យទាំងអស់
គឺមានជំនឿ មានសំនួនវោហារ មានចំណេះ មានចិត្តខ្នះខ្នែងគ្រប់យ៉ាង
ព្រមទាំងមានចិត្តស្រឡាញ់យើងផង។
ហេតុនេះ ចំពោះ ការប្រមូលតង្វាយ ចូរចំរើនឡើងយ៉ាងបរិបូណ៌ដូច្នោះដែរ។

យើងមិនផ្តល់ពរដល់ជនណាម្នាក់ឬដល់ស្ថាប័នណាមួយដើម្បីដូរយកព្រះពរពីព្រះជាម្ចាស់ទេ
ប៉ុន្តែយើងផ្តល់ពរដល់គេក្នុងនាមជាបុត្រដ៏មានពររបស់ព្រះជាម្ចាស់(blessed sons of God)
បុត្រជាទីស្រឡាញ់(his beloved sons) និងបុត្រជាទីគាប់ហប្ញទ័យ(his favored sons)។

៣.ក្រុមជំនុំរីកចម្រើនដោយសារការផ្តល់ពរ THE CHURCH EXCELS THRU GIVING

តង្វាយដែលយើងថ្វាយអាចផ្តល់ពរឲ្យក្រុមជំនុំរីកចម្រើនក្នុងវិស័យដូចជា៖

- ការបង្រៀនព្រះបន្ទូល Teaching the Word( ក្នុងក្រុមសិស្ស ក្រុមសិក្សាព្រះគម្ពីរ )
- សម្ពន្ធភាពដ៏កក់ក្តៅ Warm Fellowship( ការរួមរស់ជាមួយគ្នាជាបងប្អូន )
- ពិធីសម្ពន្ធភាពដ៏វិសុទ្ធ Holy Communion( ពិធីកាច់នំបុ័ងនៅផ្ទះនិងនៅព្រះវិហារ )
- ការអធិស្ឋាន Prayer( នៅផ្ទះ នៅព្រះវិហារ នៅកន្លែងអធិស្ឋានរួមគ្នាប្រចាំខែ )
- ការផ្សាយដំណឹងល្អ Evangelism( ម្នាក់ទល់ម្នាក់ ទ្រង់ទ្រាយតូច និងទ្រង់ទ្រាយធំ )
- ឯកភាពមកពីព្រះវិញ្ញាណ Unity of the Spirit( សកម្មភាពអ្វីដែលគាំទ្រដល់ការរួបរួម )
- ប្រយោជន៍រួម Common Good( យករបស់របរមកដាក់រួមគ្នាដើម្បីទ្រទ្រង់ក្រុមជំនុំ )
- ការរំលែកទុក្ខធុរៈគ្នា Sharing One’s Burden( យកប្រាក់មកចែកគ្នាតាមសេចក្តីត្រូវការ )
- ការប្រជុំគ្នា Meeting Together( ក្រុមមេដឹកនាំ ក្រុមស្ត្រី ក្រុមបុរស ក្រុមយុវជន ក្រុមកុមារ )
- ការថ្វាយបង្គំ Worship( សៀវភៅចម្រៀង គ្រឿងភ្លេង គ្រឿងបំពងសម្លេង ភ្លើង ។ល។ )

៤.ឥរិយាបថត្រឹមត្រូវក្នុងការផ្តល់ពរ 4. THE RIGHT ATTITUDE OF GIVING

ក.យើងផ្តល់ពរដោយផុសចេញពីចិត្តស្រឡាញ់ A. WE GIVE OUT OF LOVE

១កូរិនថូស ១៣:៣

១៣ ទោះបីខ្ញុំយកទ្រព្យសម្បត្តិរបស់ខ្ញុំទាំងប៉ុន្មានទៅចែកទានក្តី
ទោះបីខ្ញុំសុខចិត្តឲ្យគេយករូបកាយខ្ញុំទៅដុតទាំងរស់ក្តី
តែបើសិនជាខ្ញុំគ្មាន សេចក្តីស្រឡាញ់ ទេនោះក៏គ្មានប្រយោជន៍អ្វីដល់ខ្ញុំដែរ។



## ខ.យើងផ្តល់ពរដោយស្ម័គ្រអស់ពីចិត្ត

B. WE GIVE OF OUR OWN FREE WILLS

២កូរិនថូស ៨:២-៤

២ ទោះបីបងប្អូនទាំងនោះ
កំពុងជួបប្រទះទុក្ខវេទនាជាច្រើនយ៉ាងណាក្តី
ក៏គេមានអំណរខ្លាំងក្រៃលែង
ហើយទោះបីគេក្រតោកយ៉ាកយ៉ាងណាក្តី
ក៏គេនៅតែមានចិត្តសទ្ធាជ្រះថ្លាដ៏លើសលប់ដែរ។
៣ បងប្អូនទាំងនោះបានចូលប្រាក់តាមសមត្ថភាពរបស់ខ្លួន
ហើយខ្ញុំសូមបញ្ជាក់ថាគេធ្វើលើសពីសមត្ថភាព
និងដោយ ស្ម័គ្រអស់ពីចិត្ត ទៀតផង។
៤ ពួកគេបានទទូចសុំយើងមេត្តាអនុញ្ញាត
ឲ្យគេចូលរួមបំរើការងារនេះគឺផ្ញើប្រាក់ទៅជួយប្រជាជនដ៏វិសុទ្ធ។



ព្រះយេស៊ូលើកសរសើរពីស្រីមេម៉ាយម្នាក់ដែលថ្វាយដោយស្ម័គ្រអស់ពីចិត្ត។
ទោះបីតង្វាយរបស់នាងមានចំនួនតិចជាងតង្វាយរបស់ពួកអ្នកមានក៏ដោយ
ក៏នាងបានថ្វាយលើសពីសមត្ថភាពរបស់នាងទៅទៀត( លូកា ២១:១-៤ )។

គ.យើងផ្តល់ពរតាមការសម្រេចចិត្តរបស់ខ្លួនឯងផ្ទាល់

C. WE GIVE AS WE HAVE DECIDED IN OUR HEARTS

២កូរិនថូស ៩:៧

៧ ហេតុនេះ ម្នាក់ៗត្រូវតែចូលប្រាក់ តាមតែខ្លួនសំរេចចិត្ត
ដោយមិននឹកស្តាយឬ ទើសទ័លឡើយ
ដ្បិតព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្នកណាដែលធ្វើអំណោយដោយចិត្តរីករាយ។



ឃ.យើងផ្តល់ពរដោយចិត្តរីករាយ

D. WE GIVE CHEERFULLY

២កូរិនថូស ៩:៧

៧ ហេតុនេះ ម្នាក់ៗត្រូវតែចូលប្រាក់តាមតែខ្លួនសំរេចចិត្ត
ដោយមិននឹកស្តាយឬ ទើសទ័លឡើយ
ដ្បិតព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្នកណាដែលធ្វើអំណោយ ដោយចិត្តរីករាយ។





ឥរិយាបថរបស់យើងនៅក្នុងការផ្តល់ពរ( ការថ្វាយ )បញ្ជាក់ឲ្យឃើញថា
តើចិត្តរបស់យើងកំពុងតែនៅកន្លែងណាហើយជិតជាប់នឹងអ្នកណា ។

## ៥.គុណប្រយោជន៍នៃការផ្តល់ពរ 5. THE ADVANTAGE OF GIVING

### ក.ការផ្តល់ពរមានពរជាងការទទួលពរ

### A. IT IS MORE BLESSED TO GIVE THAN TO RECEIVE

កិច្ចការ ២០:៣៥

៣៥ ក្នុងគ្រប់កិច្ចការទាំងអស់ខ្ញុំតែងតែប្រាប់ឲ្យបងប្អូនដឹងថា
ត្រូវតែធ្វើការនឿយហត់បែបនេះឯងដើម្បីជួយទំនុកបម្រុងអស់អ្នកដែលក្រខ្សត់
ហើយត្រូវចងចាំព្រះបន្ទូលរបស់ព្រះអម្ចាស់យេស៊ូថា:
"បើ ឲ្យ នោះនឹងបានសុភមង្គលច្រើនជាងទទួល"»។

ការផ្តល់ពរ( giving ការថ្វាយ )មានពរបីជាន់គឺពរដល់អ្នកទទួល(the receiver)
ពរដល់អ្នកផ្តល់(the giver) និងពរដល់អ្នកតភ្ជាប់(the connector) អំណោយរបស់យើង
ជាមួយសហគមន៍(the community) ឬព្រះរាជ្យរបស់ព្រះជាម្ចាស់(the kingdom of God)
រីឯការទទួលពរវិញមានពរតែមួយជាន់គត់គឺពរដល់អ្នកទទួល។

ខ.ការផ្ដល់ពរចងចិត្តយើងឲ្យជក់ជាប់នឹងស្ថានបរមសុខ

B. GIVING BINDS OUR HEARTS AND HEAVEN TOGETHER

ម៉ាថាយ ៦:១៩-២១

១៩ «កុំសន្សំទ្រព្យសម្បត្តិទុកសំរាប់ខ្លួននៅលើផែនដី
ជាកន្លែងដែលមានកណ្ដៀរនឹងច្រែះស៊ី
ជាកន្លែងដែលមានចោរទម្លាយជញ្ជាំងចូលមកលួចប្លន់នោះឲ្យសោះ។
២០ ចូរប្រមូលទ្រព្យសម្បត្តិទុកនៅស្ថានបរមសុខវិញ
ជាស្ថានដែលគ្មានកណ្ដៀរនិងច្រែះស៊ី
ជាស្ថានដែលគ្មានចោរទម្លាយជញ្ជាំងចូលមកលួចប្លន់ឡើយ
២១ ដ្បិតទ្រព្យសម្បត្តិអ្នកនៅកន្លែងណា ចិត្តរបស់អ្នក ក៏នៅកន្លែងនោះដែរ»។

ការផ្ដល់ពរចងចិត្តយើងជាប់នឹងការសន្សំទ្រព្យសម្បត្តិទុកសម្រាប់ខ្លួនឯងនៅស្ថានបរមសុខ។
រីឯការមិនផ្ដល់ពរវិញចងចិត្តយើងជាប់នឹងការសន្សំសម្បត្តិទ្រព្យទុកសម្រាប់ខ្លួននៅលើផែនដី។

គ.ការផ្ដល់ពរជួយយើងឲ្យរក្សាឥរិយាបថដូចព្រះគ្រិស្ដ

C. GIVING HELPS US KEEP THE CHRISTLIKE ATTITUDE

ភីលីព ២:៤-៧

៤ ក្នុងចំណោមបងប្អូន ម្នាក់ៗ កុំគិតតែពីប្រយោជន៍ផ្ទាល់ខ្លួនឡើយ
គឺត្រូវគិតដល់ប្រយោជន៍អ្នកដទៃវិញ។
៥ ព្រះគ្រិស្ដយេស៊ូ មានចិត្តគំនិត យ៉ាងណា
បងប្អូនត្រូវមានចិត្តគំនិតយ៉ាងនោះដែរ។
៦ ទោះបីព្រះអង្គមានឋានៈជាព្រះជាម្ចាស់ក៏ដោយ
ក៏ព្រះអង្គពុំបានក្ដោបក្ដាប់ឋានៈដែលស្មើនឹងព្រះជាម្ចាស់នេះ
ទុកជាកម្មសិទ្ធិដាច់មុខរបស់ព្រះអង្គឡើយ។
៧ ផ្ទុយទៅវិញ ព្រះអង្គបានលះបង់អ្វីៗទាំងអស់មកយកឋានៈជាទាសករ
ព្រះអង្គបានទៅជាមនុស្សដូចមនុស្សឯទៀតៗ
ហើយក៏រស់នៅក្នុងភាពជាមនុស្សសាមញ្ញដែរ។



ព្រះគ្រិស្ដជាអ្នកផ្ដល់ពរដែលមិនគិតពីប្រយោជន៍របស់ព្រះអង្គផ្ទាល់ឡើយ
ព្រះអង្គលះបង់សិរីរុងរឿងនៅស្ថានបរមសុខនិងលះបង់ព្រះជន្មរបស់ព្រះអង្គនៅផែនដី
ដើម្បីប្រទានការសង្គ្រោះអស់កល្បជានិច្ចនិងជីវិតពេញបរិបូណ៌ដល់មនុស្សលោក។
តើយើងមានគំនិត( mind )ឬឥរិយាបថ( attitude )ជាអ្នកផ្ដល់ពរដូចព្រះគ្រិស្ដដែរឬទេ ?

ឃ.ការផ្ដល់ពរជួយយើងឲ្យសន្សំសម្បត្តិដ៏ល្អគង់វង្សសម្រាប់លោកខាងមុខ
D. GIVING HELPS US STORE UP FOR OURSELVES
A GOOD FOUNDATION FOR THE FUTURE
១ធីម៉ូថេ ៦:១៧-១៩
១៧ ចូរដាស់តឿនពួកអ្នកមាននៅលោកីយ៍នេះ
កុំឲ្យអួតខ្លួននិងយកទ្រព្យសម្បត្តិដែលមិនទៀងធ្វើជាទីសង្ឃឹមឡើយ
គឺត្រូវសង្ឃឹមលើព្រះជាម្ចាស់
ដែលប្រទានឲ្យយើងមានអ្វីៗទាំងអស់យ៉ាងបរិបូណ៌
សំរាប់ឲ្យយើងប្រើប្រាស់នោះវិញ។
១៨ ត្រូវឲ្យគេប្រព្រឹត្តអំពើល្អ ឲ្យគេធ្វើជាអ្នកមានផ្នែកខាងបុណ្យទាន
ឲ្យគេមានចិត្តទូលាយចេះចែករំលែកដល់អ្នកឯទៀតៗ
១៩ ធ្វើដូច្នេះគេនឹង សន្សំសម្បត្តិដ៏ល្អគង់វង្ស សំរាប់លោកខាងមុខ
ដើម្បីទទួលជីវិតដ៏ពិតប្រាកដ។

ង.ការផ្តល់ពរជួយឲ្យកើនដល់ចម្រូតនៃសេចក្តីសុចរិតរបស់យើង

E. GIVING HELPS INCREASE THE HARVEST OF OUR RIGHTEOUSNESS

២កូរិនថូស ៩:១០

១០ ព្រះអង្គដែល«ប្រទានគ្រាប់ពូជដល់អ្នកសាបព្រោះនិងប្រទានចំណីអាហារឲ្យគេផងនោះ»
ទ្រង់ក៏ផ្គត់ផ្គង់គ្រាប់ពូជឲ្យបងប្អូននិងឲ្យគ្រាប់ពូជនោះកើនចំនួនឡើងដែរ
ហើយព្រះអង្គនឹងធ្វើឲ្យ សេចក្តីសុចរិតរបស់បងប្អូន បង្កើតផលបានច្រើនឡើងថែមទៀត។



ច.ការផ្តល់ពរជួយអ្នកទទួលពរឲ្យអរព្រះគុណព្រះជាម្ចាស់កាន់តែច្រើនឡើង

F. GIVING HELPS THE RECEIVERS OVERFLOW IN THANKSGIVING TO GOD

២កូរិនថូស ៩:១១-១២

១១ ព្រះអង្គនឹងធ្វើឲ្យបងប្អូនទៅជាអ្នកមានគ្រប់វិស័យទាំងអស់
ដើម្បីឲ្យបងប្អូនមានចិត្តសទ្ធាជ្រះថ្លាគ្រប់ចំពូក
និងឲ្យអ្នកឯទៀតៗអរព្រះគុណព្រះជាម្ចាស់ដោយយើងជួយគេ
១២ ដ្បិតមុខងារប្រមូលប្រាក់នេះ
មិនត្រឹមតែជួយផ្គត់ផ្គង់សេចក្តីត្រូវការរបស់អ្នកជឿប៉ុណ្ណោះទេ
គឺថែមទាំងជួយគេឲ្យ អរព្រះគុណ ព្រះជាម្ចាស់កាន់តែច្រើនឡើងទៀតផង។

ការផ្តល់ពរនាំឲ្យអ្នកទទួលពរអរព្រះគុណព្រះជាម្ចាស់ដោយសារមនុស្សដែលជួយគេ។
បើយើងមានលទ្ធភាពអាចផ្តល់ពរដល់មនុស្សកាន់តែច្រើន
នោះនឹងមានមនុស្សកាន់តែច្រើនអរព្រះគុណព្រះជាម្ចាស់ដោយសារយើង។

ឆ.ការផ្តល់ពរជួយអ្នកទទួលពរឲ្យលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់
G. GIVING HELPS THE RECEIVERS GLORIFY GOD
២កូរិនថូស ៩:១៣
១៣ ពេលគេយល់តម្លៃនៃកិច្ចការដែលបងប្អូនធ្វើនេះ
គេនាំគ្នា លើកតម្កើងសិរីរុងរឿង របស់ព្រះជាម្ចាស់
ព្រោះបងប្អូនសំដែងឲ្យគេឃើញថាបងប្អូនពិតជាប្រតិបត្តិតាមដំណឹងល្អរបស់ព្រះគ្រិស្ត
ដែលបងប្អូនប្រកាស ហើយបងប្អូនមានចិត្តទូលាយ
ដោយយករបស់របរមកចែកជាមួយពួកគេនិងជាមួយមនុស្សទាំងអស់។

សួនបុប្ផាមានកម្លាំងទាក់ទាញប្អូនគឺភាពចម្រុះ( varieties )របស់បុប្ផា សោភ័ណភាព( beauty ) គន្ធពិដោរ( aroma ) និងបរិយាកាស( atmosphere )។ ការតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ក៏មានកម្លាំងទាក់ទាញប្អូនដែរគឺចំនួនអ្នកចូលរួម(attendants ) ការថ្វាយឬការផ្តល់ពរ( giving ) ព្រះបន្ទូលរបស់ព្រះជាម្ចាស់( the word of God ) និងព្រះវិញ្ញាណដ៏វិសុទ្ធ( the Holy Spirit )។

ជ.ការផ្តល់ពរជួយអ្នកទទួលពរឲ្យទូលអង្វរដោយចិត្តស្រឡាញ់
H. GIVING HELPS THE RECEIVERS GLORIFY GOD
២កូរិនថូស ៩:១៤
១៤ គេ ទូលអង្វរ ព្រះជាម្ចាស់ឲ្យបងប្អូនដោយចិត្តស្រឡាញ់
ព្រោះតែព្រះគុណដ៏ច្រើនលើសលុប
ដែលព្រះជាម្ចាស់ប្រទានមកបងប្អូន។



## ៦.ព្រះជាម្ចាស់និងទ្រព្យសម្បត្តិ 6. GOD AND WEALTH

### ក.ការប្រើប្រាស់ទ្រព្យសម្បត្តិលោកីយ៍ជះឥទ្ធិពលដល់ការប្រគល់ទ្រព្យសម្បត្តិដ៏ពិត

THE USE OF UNJUST WEALTH AFFCTS THE ENTRUSTING OF TRUE WEALTH

លូកា ១៦:១១

១១ ប្រសិនបើអ្នករាល់គ្នាមិនស្មោះត្រង់
ក្នុងរបៀបប្រើប្រាស់ទ្រព្យសម្បត្តិលោកីយ៍ដែលបញ្ឆោតចិត្តនេះទេ
ព្រះជាម្ចាស់ក៏ពុំអាចប្រគល់ ទ្រព្យសម្បត្តិដ៏ពិតប្រាកដ មកអ្នករាល់គ្នាបានដែរ។



### ខ.ទ្រព្យសម្បត្តិលោកីយ៍តែងតែប្រជែងជាមួយព្រះជាម្ចាស់ជានិច្ច

B. WORLDLY WEALTH ALWAYS RIVALS GOD

លូកា ១៦:១៣

១៣ គ្មានអ្នកណាអាចបំរើម្ចាស់ពីរនាក់បានទេព្រោះអ្នកនោះនឹងស្អប់ម្នាក់ស្រឡាញ់ម្នាក់
ស្មោះត្រង់នឹងម្នាក់មើលងាយម្នាក់ទៀតពុំខាន។
អ្នករាល់គ្នាពុំអាចគោរពបំរើ ព្រះជាម្ចាស់ ផង គោរពបំរើ ទ្រព្យសម្បត្តិលោកីយ៍ ផងបានឡើយ»។



**ពាក្យព្រមាន**

ទឹកអាចបណ្តែតទូកក៏បាននិងអាចពន្លិចទូកក៏បាន។
ភ្លើងអាចចម្អិនម្ហូបក៏បាននិងអាចកម្លោចម្ហូបក៏បាន។
លុយអាចជាបម្រើអ្នកក៏បាននិងអាចជាព្រះអ្នកក៏បាន
គឺវាអាស្រ័យលើចំណុចមួយនេះថា៖
«តើអ្នកកំពុងគ្រប់គ្រងលុយឬលុយកំពុងគ្រប់គ្រងអ្នក ?»

គ.ត្រូវចេះស្កប់ចិត្តជាមួយទ្រព្យសម្បត្តិ
C. BE CONTENTED WITH WEALTH
ភីលីព ៤:១១-១៣
១១ ខ្ញុំនិយាយដូច្នេះមិនមែនមកពីខ្ញុំខ្វះខាតទេ
ដ្បិតខ្ញុំបានរៀនឲ្យ ចេះស្កប់ចិត្ត ក្នុងគ្រប់កាលៈទេសៈ។
១២ ទោះបីទ័លក្រក្ដី មានបរិបូណ៌ក្ដី ខ្ញុំក៏ចេះរស់ដែរ។
ខ្ញុំបានអប់រំចិត្តក្នុងគ្រប់កាលៈទេសៈនិងគ្រប់ទីកន្លែង
គឺថាទោះបីបរិភោគឆ្អែតក្ដី អត់ឃ្លានក្ដី
មានបរិបូណ៌ក្ដី ឬខ្វះខាតក្ដី ខ្ញុំស្កប់ចិត្តជានិច្ច។
១៣ ខ្ញុំអាចទ្រាំបានទាំងអស់ដោយរួមជាមួយព្រះអង្គដែលប្រទានកម្លាំងឲ្យខ្ញុំ។

ការស្កប់ចិត្តជាខ្សែក្រវាត់សុវត្ថិភាពសម្រាប់ការពារយើងមិនឲ្យស្រឡាញ់ទ្រព្យសម្បត្តិលោកីយ៍។
ការមិនស្រឡាញ់ប្រាក់ជាខ្សែក្រវាត់សុវត្ថិភាពសម្រាប់ការពារយើងមិនឲ្យបម្រើម្ចាស់ពីរនាក់។

សំណួរបញ្ជាក់ការអនុវត្ត

1. តើព្រះយេស៊ូមានបំណងឲ្យអ្នកគ្រប់គ្រងប្រាក់កាសដោយរបៀបណា?
2. តើអ្នកបានទទួលពរជាក់ស្តែងអ្វីខ្លះរួមជាមួយលោកអប្រាហាំ?
3. តើអ្នកបានផ្តល់ពរដូចលោកអប្រាហាំដែរឬទេ?
4. តើអ្នកផ្តល់ពរដើម្បីដូរយកព្រះពរពីព្រះជាម្ចាស់មែនឬទេ?
   តើអ្នកផ្តល់ពរក្នុងនាមជាមនុស្សបែបណា?
5. តើអ្នកជាអ្នកផ្តល់ពរដែលនាំឲ្យរីកចម្រើនក្នុងវិស័យអ្វីខ្លះក្នុងក្រុមជំនុំអ្នក?
6. តើកន្លងមកអ្នកធ្លាប់ផ្តល់ពរក្នុងឥរិយាបថបែបណា? ចុះឥឡូវនេះវិញ?
7. តើអ្នកធ្លាប់ពិសោធនូវការអស្ចារ្យបែបណាខ្លះដែលជាផលនៃការផ្តល់ពរ?
8. តើអ្នកមានផែនការបែបណាដើម្បីឲ្យក្រុមជំនុំអ្នកកើនខាងការផ្តល់ពរ?
9. សូមទន្ទេញនិងសញ្ជឹងគិតបទគម្ពីរ ២កូរិនថូស ៨:៦-៧; ៩:៨-៩ ។